**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ**

**THE STUDENT MOVEMENT FOR DEMOCRACY**

លេខ៖០០១៣/២០ច.ន.ប្រ.

រដ្ឋធានីវ៉ាស៊ីតុន ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០

**សូមគោរពជូន**

**លោក ម៉ៃឃើល ផុមភេអូ (Michael R. Pompeo)**

**រដ្ឋមន្ត្រីនៃក្រសួងការបរទេសសហរដ្ឋអាមេរិក**

***លោករដ្ឋមន្ត្រីជាទីគោរពរាប់អាន***

យើងខ្ញុំ **ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** បានតាមដានយ៉ាងយកចិត្តទុកដាក់ចំពោះសេចក្តីថ្លែង-ការណ៍របស់លោករដ្ឋមន្ត្រី ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០ ពាក់ព័ន្ធនឹងជម្លោះសមុទ្រចិនខាងត្បូង។ លោករដ្ឋមន្ត្រី បានបញ្ជាក់ជំហរយ៉ាងម៉ឺងម៉ាត់ថា *«សហរដ្ឋអាមេរិកប្រកាន់ជំហរច្បាស់លាស់ថា ការអះអាងនានារបស់ក្រុងប៉េកាំង ក្នុងការក្តោបយកធនធាននានានៅក្នុងឈូងសមុទ្រស្ទើរតែទាំងអស់ នៅសមុទ្រចិនខាងត្បូង គឺខុសច្បាប់ទាំងស្រុង»*។ លោករដ្ឋមន្ត្រីក៏បានសង្កត់ធ្ងន់ថា *«សហរដ្ឋអាមេរិក មានផលប្រយោជន៍រួមយ៉ាងជ្រៅ និងជាចីរកាល ជាមួយដៃគូ និងសម្ព័ន្ធមិត្ត ដែលបានគាំទ្រឲ្យមានបទបញ្ជាអន្តរជាតិជាធរមាន»*។

យើងខ្ញុំសូមយកឱកាសនេះ ជម្រាបជូនលោករដ្ឋមន្ត្រី នូវការរំលោភច្បាប់សមុទ្រ ពីសំណាក់ប្រទេសវៀតណាម មកលើកម្ពុជា ក្នុងការកាន់កាប់កោះត្រល់ និងប្រជុំកោះក្រចកសេះ ដែលជាកម្មសិទ្ធិរបស់កម្ពុជា ផ្អែកតាមប្រវត្តិសាស្ត្រ ភូមិសាស្ត្រ និងច្បាប់អន្តរជាតិ។ វៀតណាម បានរំលោភលើខ្លឹមសារនៃអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីច្បាប់សមុទ្រ ឆ្នាំ១៩៨២ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសស្តីពីកម្ពុជា ឆ្នាំ១៩៩១ និងធម្មនុញ្ញអាស៊ាន។

- **អនុសញ្ញានៃអង្គការសហប្រជាជាតិ ស្តីអំពីច្បាប់សមុទ្រ ឆ្នាំ១៩៨២ (UNCLOS 1982)**
  អនុសញ្ញាស្តីអំពីច្បាប់សមុទ្រឆ្នាំ១៩៨២ ផ្នែក២ ជំពូក២ មាត្រា៣ ចែងថា *«រដ្ឋទាំងអស់មានសិទ្ធិបង្កើតប្រវែងនៃដែនសមុទ្ររបស់ខ្លួនរហូតដល់ដែនកំណត់មិនលើសពីចម្ងាយ* ***១២ ម៉ាយល៍ ឬស្មើ ២២,២២៤ គីឡូម៉ែត្រ (1 nautical miles = 1,852 meters)*** *ដែលវាស់ពីខ្សែបន្ទាត់មូលដ្ឋានដែនកំណត់អនុលោមតាមអនុសញ្ញានេះ»*។

  យោងតាមអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីអំពីច្បាប់សមុទ្រឆ្នាំ១៩៨២ នេះ និងតាមលក្ខខណ្ឌភូមិសាស្ត្រ **កោះត្រល់ (វៀតណាមហៅថា Phú Quốc) គឺជាកម្មសិទ្ធិរបស់ប្រទេសកម្ពុជា ពីព្រោះដីដុះបន្តពីជួរភ្នំក្រវាញនៃខេត្តកំពត តភ្ជាប់ទៅដល់កោះត្រល់ ហើយនិងមានរយៈចម្ងាយត្រឹមតែ ១៥ គីឡូម៉ែត្រ ពីឆ្នេរសមុទ្រនៃខេត្តកំពត ប្រទេសកម្ពុជា គឺស្ថិតក្នុងរង្វង់ដែន ២២,២២៤ គីឡូម៉ែត្រ ដែលកំណត់ដោយច្បាប់សមុទ្រនេះ។ ប៉ុន្តែកោះត្រល់ មានរយៈចម្ងាយរហូតដល់ ៤៥ គីឡូម៉ែត្រ ពីតំបន់ហាទៀង នៃខេត្តកៀនយ៉ាង ប្រទេសវៀតណាម ដែលស្ថិតនៅផ្នែខាងក្រៅរង្វង់ដែន ២២,២២៤ គីឡូម៉ែត្រ កំណត់ដោយច្បាប់សមុទ្រនេះ។**

- **កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ១៩៩១ (PPA 1991)**
  ឯកសារទី២ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស មាត្រា១ ចំណុច២-ឃ ចែងថា *«បញ្ចប់សន្ធិសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយ ដែលមិនស្របអធិបតេយ្យភាព ឯករាជ្យ បូរណភាព និងភាពមិនអាចរំលោភបាន នៃដែនដីអព្យាក្រឹតភាព និង ឯកភាពជាតិរបស់ខ្លួន»*។

  សន្ធិសញ្ញា និងកិច្ចព្រមព្រៀង ធ្វើឡើងនៅឆ្នាំ១៩៧៩ ១៩៨២ ១៩៨៣ និងឆ្នាំ១៩៨៥ រវាងវៀតណាម-កម្ពុជា ក្រោមស្ថានភាពដែលកម្ពុជាត្រួតត្រាដោយកងទ័ពវៀតណាម បានក្លាយជាមោឃភាពអស់ហើយ ដោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ ប៉ុន្តែរដ្ឋាភិបាលវៀតណាម និងរដ្ឋាភិបាលកម្ពុជា នៅតែយកមកធ្វើជាមូលដ្ឋានដោះស្រាយជម្លោះព្រំដែនវៀតណាម-កម្ពុជា។ រីឯសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ និងឆ្នាំ២០១៩ ដែលរដ្ឋាភិបាលកម្ពុជាសព្វថ្ងៃប្រើជាបង្អែកដែរនោះ ក៏មានខ្លឹមសារបំពានទាំងស្រុង លើកិច្ចព្រមព្រៀងទីក្រុងប៉ារីសនេះដែរ។

កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ គឺជាលិខិតូបករណ៍អន្តរជាតិ ឬមានតម្លៃជាច្បាប់អន្តរជាតិ ដែលប្រទេសហត្ថលេខីទាំងអស់ ត្រូវអនុវត្តឲ្យត្រូវខ្លឹមសារដោយការគោរពគ្នាជាចាំបាច់។ វៀតណាម និងសមាជិកនៃសមាគមអាស៊ានភាគច្រើន គឺជាប្រទេសហត្ថលេខីនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសស្តីពីកម្ពុជានេះ។

- **គោលការណ៍អាស៊ាន (ASEAN Principles)**
  ធម្មនុញ្ញអាស៊ាន មាត្រា២ ចំណុច២ ចែងថា*«អាស៊ាន និងរដ្ឋសមាជិក ត្រូវអនុវត្តឲ្យសមស្របតាមគោល-ការណ៍៖ ក). គោរពឯករាជ្យភាព អធិបតេយ្យភាព សមភាព បូរណភាពទឹកដី និងអត្តសញ្ញាណជាតិ នៃរដ្ឋសមាជិកអាស៊ានទាំងអស់។ ខ). ចូលរួមការប្តេជ្ញាចិត្ត និងការទទួលខុសត្រូវរួមគ្នាក្នុងការលើកកម្ពស់សន្តិភាព សន្តិសុខ និងវិបុលភាពក្នុងតំបន់។ គ). បដិសេធនូវអំពើឈ្លានពាន និងការគំរាមកំហែង ឬការប្រើប្រាស់កម្លាំង ឬសកម្មភាពទាំងឡាយណា ក្នុងលក្ខណៈដែលមិនសមស្របតាមច្បាប់អន្តរជាតិ។»*។

នៅក្នុងសេចក្តីថ្លែងការណ៍ទៅកាន់អង្គការសហប្រជាជាតិ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៨៧ **សហរដ្ឋអាមេរិក បានតវ៉ាជំទាស់នឹងកិច្ចព្រមព្រៀងតំបន់ទឹកប្រវត្តិសាស្ត្រ ដែលមេដឹកនាំរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងវៀតណាម បានចុះហត្ថលេខារួមគ្នា ថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៨២ ដែលបានកាត់ផ្តៀលយកកោះត្រល់ និងចង្កោមកោះក្រចកសេះរបស់កម្ពុជា ដោយរំលោភបំពានលើអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីច្បាប់សមុទ្រ ឆ្នាំ១៩៨២។ ប្រទេសថៃ សិង្ហបុរី និងប្រទេសអាល្លឺម៉ង់ ក៏បានតវ៉ាជំទាស់នឹងកិច្ចព្រមព្រៀងតំបន់ទឹកប្រវត្តិសាស្ត្រនេះ** ដូចជំហរសហរដ្ឋអាមេរិកដែរ។

លោក **វ៉លធ័រ ឡូម៉ែន** (Walter Lohman) និងអ្នកស្រី **អូលីវា អ៊ីនូស** (Olivia Enos) អ្នកសិក្សាស្រាវជ្រាវនៅតំបន់អាស៊ី នៃមូលនិធិបេតិកភណ្ឌ (The Heritage Foundation) ជាអង្គការធនាគារគំនិត ដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិក បានបញ្ជាក់ក្នុងសារណារបស់ខ្លួន ចុះផ្សាយថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ ថា *«អ្វីដែលកើតឡើងនៅកម្ពុជា គឺមានសារៈសំខាន់ចំពោះសហរដ្ឋអាមេរិក។ ពីសង្គ្រាមវៀតណាម ដល់សង្គ្រាមត្រជាក់ និងតួនាទីក្នុងអាស៊ាន កម្ពុជាបានក្លាយជាផ្នែកមួយដ៏មានសារៈសំខាន់ នៅក្នុងគោលនយោបាយការបរទេសសហរដ្ឋអាមេរិក»*។ សហរដ្ឋអាមេរិកជាប្រទេសហត្ថលេខី នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដែលត្រូវមានកាតព្វកិច្ចតាមឃ្លាំមើលដំណើរការ នៃការអនុវត្តលទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជា ជាពិសេសធានាសន្តិសុខ ស្ថិរភាព និងសន្តិភាពនៅក្នុងតំបន់។

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** សូមបញ្ជាក់បន្ថែម ជូនលោករដ្ឋមន្ត្រី **ម៉ៃឃើល ផុមភេអូ** (Michael R. Pompeo) ថា វៀតណាមមានប្រវត្តិជាប់មិនដាច់គ្រប់ដំណាក់កាល ក្នុងការឈ្លានពានប្រទេសកម្ពុជា ចូលកាន់កាប់ដែនដីគោកតាមបណ្តោយព្រំដែន ដែនសមុទ្រ និងកោះនានារបស់កម្ពុជា ព្រមទាំងបង្ហូរជនជាតិវៀតណាមខុសច្បាប់រាប់លាននាក់ ទៅរស់នៅលើទឹកដីកម្ពុជា ដោយការគប់គិតគ្នារវាងអាជ្ញាធរកម្ពុជា និងរដ្ឋាភិបាលវៀតណាមទាំងរំលោភបំពានលើច្បាប់ជាតិ-អន្តរជាតិ ដែលមានជាធរមាន។ ស្របពេលកុម្មុយនិស្តចិន កំពុងចាក់គ្រឹះអំណាចផ្តាច់ការលប់លើតំបន់អាស៊ីនោះ ប្រទេសវៀតណាមក៏នៅតែសាបព្រោះមនោគមវិជ្ជាកុម្មុយនីស្តរបស់ខ្លួនរាលដាលគ្របដណ្តប់លើអំណាចដឹកនាំនៅកម្ពុជា និងឡាវ ដែលគំរាមកំហែងយ៉ាងខ្លាំងដល់អនាគតអាយុជីវិតទឹកដីនៃប្រទេសទាំងពីរ។ គ្រឹះឥទ្ធិពលកុម្មុយនិស្តចិន និងវៀតណាមនេះ បង្កការគំរាមកំហែងដល់ ស្ថិរភាពក្នុងតំបន់ ដែលផ្ទុយពីជំហររបស់សហរដ្ឋអាមេរិក ក្នុងការពង្រីកវិសាលភាពនៃសេរីភាព សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ។

អាស្រ័យដូចអំណះអំណាងរៀបរាប់សង្ខេបខាងលើ យើងខ្ញុំសូមស្នើលោករដ្ឋមន្ត្រី មេត្តាបញ្ជាក់ឡើងវិញ នូវជំហររបស់សហរដ្ឋអាមេរិក ដូចក្នុងឆ្នាំ១៩៨៧ ក្នុងការជំទាស់នឹងកិច្ចព្រមព្រៀងតំបន់ទឹកប្រវត្តិសាស្ត្រ ឆ្នាំ១៩៨២ និងសូមប្រកាសជំហរទទួលស្គាល់ជាផ្លូវការថា កោះត្រល់ និងចង្កោមកោះក្រចកសេះ ជាកម្មសិទ្ធិរបស់ប្រទេសកម្ពុជា។

សូមលោករដ្ឋមន្ត្រី **ម៉ៃឃើល ផុមភេអូ** (Michael R. Pompeo) ទទួលនូវការគោរពរាប់អានអំពីយើងខ្ញុំ។

**ប្រធានប្រតិបត្តិ**

**ទូច វិបុល**